មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

**វិចារណៈកថាព័ត៌មានរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា**

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៣

**ម.ស.ម.ក លើកឡើងនូវក្តីព្រួយបារម្ភអំពីកូដកម្មដែលមានការកើនឡើង នៅតាម បណ្តារោងចក្រកាត់ដេរ នៅក្នុងឆ្នាំ២០១៣នេះ**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា("ម.ស.ម.ក") មានការព្រួយបារម្ភដោយមានការចេញផ្សាយព័ត៌មាននាពេលថ្មីៗនេះ ក្នុងទំព័រសារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ ("កូដកម្មក្នុងរោងចក្រនៅកម្ពុជាអាចប៉ះពាល់ដល់ការបញ្ជាទិញ") ដោយមានការបង្ហាញថា មានកម្មករប្រហែលជា ១០.០០០ (មួយម៉ឺន) នាក់ បានធ្វើកូដកម្មនៅរោងចក្រចំនួនប្រាពីរ ឬប្រាំបី ចាប់តាំងពីដើមឆ្នាំ២០១៣ មក ក្នុងគោលបំណងទាមទារឲ្យមានការតម្លើងប្រាក់ឈ្នួលអប្បបរមា និងទាមទារឲ្យមានការកែលម្អលក្ខខណ្ឌការងារ។ មានការតវ៉ាដោយឡែកពីគ្នាមួយផ្សេងទៀតបានចាប់ផ្តើមនៅថ្ងៃទី១២ មករា ២០១៣ ដើម្បីទាមទារឲ្យមេដឹកនាំសហជីពរោងចក្រចំនួនប្រាំនាក់ដែលត្រូវបានរោងចក្របណ្តេញចេញ ឲ្យចូលបម្រើការដូចដើមវិញ។ ការតវ៉ានេះ ឈានទៅដល់ការបញ្ឈប់ការងារជាទ្រង់ទ្រាយធំមួយទៅលើកម្មករប្រហែលចំនួន៩០០នាក់ ដែលចូលរួមក្នុងធ្វើការតវ៉ានោះ។ ទោះបីជា ម.ស.ម.ក គាំទ្រយ៉ាងខ្លាំងទៅលើ សិទ្ធិនៃការប្រមូលផ្តុំដោយសន្តិវិធី ដែលទទួលបានការការពារដោយមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ដូចជា គោលការណ៍ជាមូលដ្ឋានទីមួយ (សេរីភាពនៃសមាគម) នៃសេចក្តីប្រកាសរបស់អង្គការពលកម្មអន្តរជាតិ ស្តីពីគោលការណ៍ និងសិទ្ធិជាមូលដ្ឋាននៅកន្លែងការងារក៏ដោយ ក៏ព្រឹត្តិការណ៍ទាំងអស់នេះ ជាការបង្ហាញយ៉ាងច្បាស់នូវនិន្នាការនៃការកើនឡើងក្នុងការធ្វើកូដកម្មនិងការជំទាស់តវ៉ា ក្នុងខណៈពេលដែលមិនមានការផ្តល់សំណង ឬ យន្តការដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធភាព ដោយផ្អែកលើនីតិរដ្ឋដ៏រឹងមាំទេនោះ។

ឧស្សាហកម្មកាត់ដេរកម្ពុជា មានការទទួលខុសត្រូវមួយក្នុងការគោរពសិទ្ធិមនុស្ស។ ការទទួលខុសត្រូវនោះ តាមការកំណត់ក្រោម "សសរស្តម្ភ" ទីពីរ នៃ ក្របខណ្ឌអង្គការសហប្រជាជាតិ ស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស។ ការកើនឡើងនៃចំនួនកូដកម្ម របស់កម្មកររោងចក្រនេះ បង្ហាញឲ្យឃើញថា រោងចក្រកំពុងខ្វះការទទួលខុសត្រូវនេះ។ ទោះជាយ៉ាងណាក៏ដោយ ធុរកិច្ចដែលគោរពសិទ្ធិមនុស្ស ជាពិសេស គោរពតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស (ដែលអនុវត្តក្របខណ្ឌរបស់អង្គការសហប្រជាជាតិ និងដែលត្រូវបានអនុម័តយល់ព្រមជាឯកច្ឆ័ន្ទដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

កាលពីខែមិថុនាឆ្នាំ២០១១នោះ) នឹងទទួលបានផលប្រយោជន៍យ៉ាងច្រើន។ ប្រការដែលគួរឲ្យចាប់អារម្មណ៍ខ្លាំងនោះ គឺថា ការដែលរោងចក្រយល់ដឹងកាន់តែប្រសើរឡើងអំពីសិទ្ធិមនុស្ស វានឹងកាត់បន្ថយការធ្វើកូដកម្ម និងការតវ៉ារបស់កម្មករជាក់ជាពុំខាន។ ប្រការនេះ នឹងធ្វើឲ្យកិត្តិសព្ទរបស់រោងចក្រកាន់តែមានភាពប្រសើរឡើង និងបង្កើននូវស្ថេរភាពខ្សែសង្វាក់ផលិតកម្ម ហើយចុងបញ្ចប់នឹងទទួលបានប្រាក់ចំណេញកាន់តែប្រសើរ។

**ជាការឆ្លើយតប លោក សុខ លាំង មន្ត្រីសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្សរបស់ ម.ស.ម.ក មានប្រសាសន៍ថា៖**

*"នៅពេលដែលចំនួនកូដកម្មករមានការកើនឡើងច្រើនបែបនេះ វាក៏គឺជាពេលវេលាសម្រាប់រោងចក្រកាត់ដេរ និងរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើការជាមួយគ្នា ដើម្បីស្វែងរកឲ្យបាននូវដំណោះស្រាយដ៏ប្រសើរ ដែលមិនត្រឹមតែការពារសិទ្ធិកម្មករតែប៉ុណ្ណោះទេ ហើយថែមទាំងធ្វើឲ្យប្រសើរដល់កិត្តិសព្ទនិងការចំណេញសម្រាប់ឧស្សាហកម្មមួយនេះទៀតផង។ នាពេលបច្ចុប្បន្ននេះ ឧស្សាហកម្មនេះ រួមទាំងកិត្តិសព្ទរបស់ប្រទេសកម្ពុជាផង កំពុងតែត្រូវបានយាយីបន្ថែមទៀតដោយសារតែឧបទ្ទវហេតុនិមួយៗទាំងនេះ។ នេះក៏ជាការកិច្ចរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការពារសិទ្ធិមនុស្ស និងជាការទទួលខុសត្រូវរបស់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស ព្រមទាំងដើម្បីធានាថា កម្មករទទួលបាននូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព នៅពេលការរំលោភបំពានសិទ្ធិមនុស្សកើតឡើង។ ដោយសារតែឧស្សាហកម្មកាត់ដេរជាចំណែកដ៏មានតម្លៃបំផុតសម្រាប់សេដ្ឋកិច្ចប្រទេសកម្ពុជានោះ ការសម្រេចបានផ្នែកសិទ្ធិមនុស្សនៅក្នុងឧស្សាហកម្មនេះ នឹងរួមចំណែកបង្កឲ្យមានឥទ្ធិពលវិជ្ជមានដល់សេដ្ឋកិច្ចប្រទេសកម្ពុជាទាំងមូល"។*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សុខ លាំង តាមទូរសព្ទ +៨៥៥(០)១២ ៥៨៨ ០៨១ ឬអ៊ីម៉េល sokleang@cchrcambodia.org ឬលោក រ៉ូប៊ើត ហ្វីនច៍ ទីប្រឹក្សាជាន់ខ្ពស់ តាមទូរសព្ទ +៨៥៥ (០)៧៨ ៨០៩ ៩៦០ឬ អ៊ីម៉េល៖ robert.finch@cchrcambodia.org។**

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ទនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) ដែលជាបណ្តាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព"។